ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១៣០០ អពដ

សារលិខិតថ្វាយព្រះពរ
សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុ
សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ក្នុងឱកាសព្រះរាជពិធីចម្រើនព្រះជន្មគម្រប់ ៧៨ព្រះវស្សា យាងចូល ៧៩ព្រះវស្សា

ក្នុងឱកាសដ៏មហានក្ខត្តឫក្សប្រសើរថ្លៃថ្លា ប្រកបដោយមនោសញ្ចេតនាដ៏សែនសោមនស្សរីករាយនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៧៨ព្រះវស្សា យាងចូល ៧៩ព្រះវស្សា នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៤ ខាងមុខ តាងនាមថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអគ្គនាយកដ្ឋានពន្ធដារ ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់សម្តែងនូវអំណរសាទរឥតឧបមា ប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជាទីបំផុត ចំពោះព្រះមហាករុណាធិគុណ និងសូមព្រះបរមរាជានុញ្ញាតថ្វាយនូវព្រះសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ គ្រប់ប្រការចំពោះ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាព ល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ចាកផុតនូវព្រះរោគាព្យាធិទាំងឡាយ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏មហាត្រជាក់ដល់កូន ចៅ ចៅទួតនៃព្រះអង្គអស់កាលជាដរាបរៀងទៅ ។

ស្ថិតក្នុងឱកាសដ៏មហាជ័យមង្គល សិរីសួស្តី ប្រពៃថ្លៃថ្លា វិសេសវិសាលនេះផងដែរ ទូលព្រះបង្គំជាខ្ញុំ សូមលំអោនកាយវាចាចិត្ត លើកកំបង់អញ្ជលីប្រណម្យបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុសក្តិសិទ្ធិក្នុងលោក ទេព្តាថែរក្សាឆ្នាំថ្មី ទេព្តាថែរក្សាព្រះមហាស្វេតឆ័ត្រ ទេព្តាថែរក្សាព្រះបរមរាជវាំង ព្រះបារមីព្រះវិញ្ញាណក្ខ័ន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីគ្រប់ព្រះអង្គ ជាពិសេស ព្រះបារមីព្រះវិញ្ញាណក្ខ័ន្ធព្រះករុណា ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ ទេព្តាទាំងមួយម៉ឺនលោកធាតុ សូមព្រះអង្គតាមជួយប្រោះព្រំបីបាច់អភិបាលថែរក្សា ប្រទានព្រះសព្ទសាធុការពរជ័យគ្រប់ប្រការថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី** សូមព្រះអង្គទ្រង់សមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ទ្រង់ព្រះមេត្តាទទួលនូវអភិវន្ទនាការដ៏ខ្ពង់ខ្ពស់ ប្រកបដោយភក្តីភាពដ៏ស្មោះស្ម័គ្របំផុត ពីទូលព្រះបង្គំជាខ្ញុំ

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល